# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Dec-2012, 11:38
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបជាបន្ទាន់របស់សហព្រះរាជអាជ្ញា ទៅនឹងសំណើររបស់ អៀង សារី ពាក់ព័ន្ធនឹងសក្ខីកម្ម តាមរយៈ ប្រព័ន្ធសោតទស្សន៍ សម្រាប់សាក្សី TCCP-1, ដោយមានឧបសម្ព័ន្ធ

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម

លោក Michael
G.KARNAVAS
លោក គង់ សំអុន
Anta GUISSÉ
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

១- នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) បានជូនដំណឹងដល់ភាគីនានាថាខ្លួនបានពិចារណាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប គឺដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 ជាបុគ្គលដែលនៅក្នុងចំណោមបុគ្គលដែល “មានភាពពាក់ព័ន្ធបំផុត” ទៅនឹងផ្នែកនានានៃសវនាការពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដូច្នេះ “ទំនងនឹងត្រូវផ្តល់សក្ខីកម្មនៅសវនាការ”[1]។ តាមអនុស្សរណៈចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ និងត្រូវបានដាក់ចំណាត់ថ្នាក់ *សម្ងាត់បំផុត* អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (“WESU”) បានរាយការណ៍អំពីការប្រាស្រ័យទាក់ទងរបស់ខ្លួនជាមួយដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 ហើយបានផ្តល់ប្រឹក្សាជូនដល់អង្គជំនុំជម្រះថាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះសុំឱ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្ម “តាមរយៈប្រព័ន្ធសោតទស្សន៍” (“សំណើសុំតាមរយៈប្រព័ន្ធសោតទស្សន៍”)[2]។ អនុស្សរណៈនេះត្រូវបានធ្វើចំណាត់ថ្នាក់ក្រោយមកទៀតជា *សម្ងាត់* ហើយបានជូនដំណឹងដល់ភាគីនានាកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ បន្ទាប់ពីអង្គជំនុំជម្រះបានអនុញ្ញាតឱ្យមានសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 តាមរយៈប្រព័ន្ធសោតទស្សន៍ (“សេចក្តីសម្រេច”)[3]។

២- នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ ដូចដែលបានអះអាងថាពិតនៅក្នុងសំណើ[4] មេធាវីការពារក្តីបានផ្តល់ប្រឹក្សាជូនដល់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង អំពីបំណងរបស់ខ្លួននៅក្នុងការទទួលយកសេចក្តីណែនាំពីជនជាប់ចោទ ស្តីពីការជំទាស់ជាសក្តានុពលនានា តាមរយៈប្រព័ន្ធសោតទស្សន៍។ កំណត់ត្រានោះបញ្ជាក់ថា ពុំមានការជំទាស់ភ្លាមៗណាមួយ ពីសំណាក់មេធាវីការពារក្តីក្នុងរយៈពេល១០ថ្ងៃខាងមុខនេះនោះឡើយ។ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់បានផ្តល់

[1] ឯកសារលេខ **E236/1** អនុស្សរណៈផ្ញើទៅកាន់ភាគីនានា៖ “ការបញ្ជាក់ជាបឋមអំពីបុគ្គលដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងអំឡុងសវនាការលើចំណុចអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងសំណុំរឿង០០២/០១”, ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ ត្រង់កថាខណ្ឌទី១។

[2] ឯកសារលេខ **E236/1/1** អនុស្សរណៈពីមន្ត្រីសម្របសម្រួល, WESU ផ្ញើទៅកាន់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង “សម្ងាត់៖ សំណើសុំឱ្យដើមបណ្តឹងរដ្ឋប្បវេណី [ឈ្មោះត្រូវបានលុបចេញ] (រហស្សនាម TCCP-1) ធ្វើសក្ខីកម្មតាមរយៈប្រព័ន្ធសោទស្សន៍, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ត្រង់កថាខណ្ឌទី៣។

[3] ឯកសារលេខ **E236/1/1/1** អនុស្សរណៈផ្ញើទៅកាន់ភាគីនានា៖ “សំណើសុំឱ្យដើមបណ្តឹងរដ្ឋប្បវេណី [ឈ្មោះត្រូវបានលុបចេញ] (រហស្សនាម TCCP-1) ធ្វើសក្ខីកម្មតាមរយៈប្រព័ន្ធសោទស្សន៍, ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២។

[4] ឯកសារលេខ **E236/1/1/2** សំណើរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្ហាញមូលហេតុឱ្យបានគ្រប់គ្រាន់ចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 ធ្វើសក្ខីកម្មតាមរយៈប្រព័ន្ធសោទស្សន៍ ឬ បើពុំដូច្នោះទេ ឱ្យធ្វើសេចក្តីសម្រេចកែប្រែវិញ ហើយធ្វើការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 ឱ្យមកផ្តល់សក្ខីកម្មដោយផ្ទាល់, ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ត្រង់កថាខណ្ឌទី១៩។

ប្រឹក្សាជូនដល់ភាគីនានា អំពីកាលវិភាគសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-1 នៅថ្ងៃទី១២ និង១៣ ខែធ្នូ ឆ្នាំ២០១២[5]។ ឥឡូវនេះ មេធាវីការពារក្ដីរបស់ អៀង សារី ("មេធាវីការពារក្ដី") ស្នើសុំឱ្យអង្គជំនុំជម្រះផ្ដល់មូលហេតុបន្ថែមទៀតរបស់ខ្លួន ក្នុងការធ្វើសេចក្ដីសម្រេចនេះ ឬបើពុំដូច្នោះទេ សុំឱ្យកែប្រែសេចក្ដីសម្រេចរបស់ខ្លួនវិញ ហើយកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី TCCP-1 ឱ្យមកផ្ដល់សក្ខីកម្មដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ ("សំណើ")[6]។

៣- ពាក់ព័ន្ធនឹងការចាប់ផ្ដើមសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-1 ដែលបានចាត់ជាកាលវិភាគនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ និងដើម្បីដាក់សេចក្ដីសន្និដ្ឋានត្រឹមត្រូវនានាស្ដីពីច្បាប់ជាធរមាន មុននឹងការចាប់ផ្ដើមសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ សហព្រះរាជអាជ្ញាសូមដាក់ជូនចម្លើយតបនេះ ក្នុងពេលនេះ។ សហព្រះរាជអាជ្ញាសូមស្នើអង្គជំនុំជម្រះ ដោយគោរពថា សូមអង្គជំនុំជម្រះអនុញ្ញាតឱ្យមានការដាក់សេចក្ដីសន្និដ្ឋាននេះជាភាសាអង់គ្លេសតែប៉ុណ្ណោះ ដោយមានអត្ថបទជាភាសាខ្មែរនឹងត្រូវដាក់ជូនអង្គជំនុំជម្រះនៅពេលក្រោយ ដោយស្របតាមមាត្រា៧.២ នៃសេចក្ដីណែនាំអនុវត្តដែលកំពុងនៅជាធរមាន[7]។ សំណើនេះត្រូវបានអនុញ្ញាត ហើយអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថាបញ្ហានេះជាបញ្ហាដែលត្រូវដោះស្រាយជាបន្ទាន់[8]។ សហព្រះរាជអាជ្ញាសូមស្នើបន្ថែមទៀតថា សេចក្ដីសន្និដ្ឋាននេះត្រូវដាក់ចំណាត់ថ្នាក់ថាជា *សាធារណៈ* ដោយសារមិនមានព័ត៌មានសម្ងាត់ណាមួយពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណីនោះឡើយ ហើយពាក់ព័ន្ធសំខាន់ពីច្បាប់ជាធរមាន ក្នុងបញ្ហាពាក់ព័ន្ធទៅនឹងប្រសិទ្ធភាព និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះ។

៤- សហព្រះរាជអាជ្ញាសូមជូនសេចក្ដីសន្និដ្ឋានថា គេត្រូវបដិសេធសំណើនេះចោលទាំងស្រុង ហើយគេត្រូវបន្តធ្វើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-1 តាមរយៈប្រព័ន្ធសោតទស្សន៍ ដូចដែលបានគ្រោងតាមកាលវិភាគ។ ដោយស្របគ្នាជាមួយនឹងវិធាននីតិវិធីដែលបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ វិធាន២៦.១នៃវិធានផ្ទៃក្នុង បានផ្ដល់ដល់អង្គជំនុំជម្រះនូវអំណាចឆន្ទានុសិទ្ធិ នៅក្នុងការ

[5] អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើទៅកាន់ភាគីនានា៖ "កាលវិភាគសាក្សីសម្រាប់ខែធ្នូ", ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២។

[6] ឯកសារលេខ **E236/1/1/2** សំណើ, កំណត់សម្គាល់*ខាងលើ* លេខ៤ ត្រង់កថាខណ្ឌទី១៩។

[7] សេចក្ដីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៨ "ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក", ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២។

[8] អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើទៅកាន់ភាគីនានា៖ "យោង៖ សំណោចម្លងស្ដីពីការដាក់ឯកសារទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណី TCCP-1 ដែលនឹងត្រូវដាក់ឱ្យបានយ៉ាងឆាប់នៅពេលដែលការបកប្រែភាសាបានបញ្ចប់", ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១២, ដែលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងមានបំណងធ្វើការដោះស្រាយលើបញ្ហានេះជាបញ្ហាបន្ទាន់មួយ"។

បង្គាប់ឲ្យមានសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍។ ការស្ទង់មតិមួយស្តីពីយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) ដែលមាននៅក្នុង **ឧបសម្ព័ន្ធទី១** បង្ហាញថា គេត្រូវធ្វើសេចក្តីសម្រេចបែបដូច្នេះ ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ ហើយថាសុខភាពមិនល្អ ឬទុក្ខព្រួយដែលឆាប់រំជួលចិត្តរបស់ជនរងគ្រោះ-សាក្សី គឺជាកត្តាទាក់ទងនៅក្នុងការវាយតម្លៃនេះ។ មិនមែនជា *អង្គហេតុ* នៃសុខភាពមិនល្អដែលជាការចាប់អារម្មណ៍ ដោយផ្ទាល់របស់អង្គជំនុំជម្រះនោះទេ ជាងនេះទៅទៀត *អសមត្ថភាព ឬភាពមិនស្ម័គ្រចិត្ត* របស់សាក្សីធ្វើដំណើរមកផ្តល់សក្ខីកម្មដោយផ្ទាល់ អាចត្រូវបានបង្ហាញដោយមូលហេតុទូលំទូលាយជាង ដូចជា សុខភាពមិនល្អ អារម្មណ៍ទុក្ខព្រួយ ឬ ការខ្វល់ខ្វាយពីបញ្ហាសន្តិសុខផ្ទាល់ខ្លួន ឬគ្រួសារ។

៥- មូលហេតុទាំងនេះអាចនឹងត្រូវបានបង្ហាញដោយវិញ្ញាបនប័ត្រវេជ្ជសាស្ត្រ របាយការណ៍របស់អង្គភាពគាំពារសាក្សីជំនាញ ឬសូម្បីតែសេចក្តីប្រកាសដោយផ្ទាល់របស់សាក្សីទាំងនោះក៏ដោយ។ អង្គជំនុំជម្រះនានានៃតុលាការ ICTY ក៏បានរកឃើញដូចៗគ្នាផងដែរថា សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ គឺមិនមានការរំលោភណាមួយទៅលើសិទ្ធិរបស់ជនជាប់ចោទនៅក្នុងការតទល់ និងការសួរដេញដោលនោះឡើយ, មិនប៉ះពាល់ដល់ជនជាប់ចោទ និងស្របទៅនឹងតម្លៃជាភស្តុតាងដូចគ្នានឹងសក្ខីកម្មនៅក្នុងតុលាការដែរ។ ពិតមែនហើយ វិធីសាស្ត្រ ចំពោះសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ គឺដើម្បីជំរុញឲ្យមុខងាររបស់តុលាការក្នុងការស្វែងរកការពិត ដែលត្រូវបានគាំទ្រយ៉ាងទូលំទូលាយនៅក្នុងប្រព័ន្ធយុត្តិធម៌ក្នុងស្រុក ជាងប្រពៃណីច្បាប់សំខាន់ៗទាំងអស់នៅក្នុងពិភពលោក។

## II. សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ គឺស្របគ្នាទាំងស្រុងទៅនឹងសិទ្ធិរបស់ជនជាប់ចោទ

៦- វិធាន២៦ នៃវិធានផ្ទៃក្នុង ចែងថា៖

> *សក្ខីកម្មរបស់សាក្សី ឬអ្នកជំនាញនៅក្នុងអំឡុងពេលស៊ើបសួរ ឬការជំនុំជម្រះត្រូវធ្វើឡើងដោយមានវត្តមានរបស់បុគ្គលនោះផ្ទាល់ នៅពេលណាដែលអាចធ្វើទៅបាន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចអនុញ្ញាតឱ្យសាក្សីផ្តល់សក្ខីកម្មតាមរយៈបច្ចេកវិទ្យាសោតទស្សន៍ ឬទូរទស្សន៍ ក្នុងករណីដែលបច្ចេកវិទ្យាបែបនោះ អនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ និងភាគីសាកសួរសាក្សីបាន នៅពេលដែលសាក្សីត្រូវឡើងធ្វើសក្ខីកម្ម។ បច្ចេកវិទ្យានេះមិនត្រូវអនុញ្ញាតឱ្យប្រើទេ ប្រសិនបើធ្វើឱ្យមានអន្តរាយធ្ងន់ធ្ងរ ឬមិនស្របទៅនឹងសិទ្ធិការពារខ្លួន។*

៧- វិធាន២៦នៃវិធានផ្ទៃក្នុង ឆ្លុះបញ្ចាំងពីវិធាននីតិវិធីផ្សេងទៀតដែលបានអនុម័តក្នុងកម្រិតអន្តរជាតិ ក្នុងការទទួលស្គាល់ទាំងការផ្តល់សក្ខីកម្មជាបុគ្គលដោយផ្ទាល់ និងឆន្ទានុសិទ្ធិតុលាការក្នុងអនុញ្ញាតឱ្យផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍។ ជាឧទាហរណ៍ តាមវិធាន៨១*ស្ទួន* របស់តុលាការ ICTY "តាមសំណើរបស់ភាគីមួយ ឬ*តាមគំនិតផ្ទាល់របស់អង្គជំនុំជម្រះ* ចៅក្រម ឬអង្គជំនុំជម្រះអាចបង្គាប់ឱ្យកិច្ចដំណើរការនីតិវិធីធ្វើតាមរយៈប្រព័ន្ធសោតទស្សន៍បាន បើសិនជាស្របទៅនឹងផលប្រយោជន៍នៃយុត្តិធម៌"។

៨- ដូចមេធាវីការពារក្តីបានផ្តល់អត្តសញ្ញាណត្រឹមត្រូវដែរ[9] ករណីយុត្តិសាស្ត្ររបស់តុលាការ ICTYបង្កើតនូវលក្ខណៈវិនិច្ឆ័យចំនួនបីសម្រាប់ណែនាំដល់អង្គជំនុំជម្រះ ពេលធ្វើការសម្រេចថាតើសាក្សីគួរត្រូវបានអនុញ្ញាតឱ្យផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ដែរ ឬទេគឺ (១) សាក្សីរូបនោះត្រូវតែមិនអាច ឬមានហេតុផលល្អក្នុងការបញ្ជាក់ពីឆន្ទៈមិនចង់មកកាន់តុលាការ, (២) សក្ខីកម្មរបស់សាក្សីរូបនោះ ត្រូវតែមានសារៈសំខាន់គ្រប់គ្រាន់ ដើម្បីធ្វើឱ្យសក្ខីកម្មរបស់សាក្សីរូបនោះមានភាពអយុត្តិធម៌ដល់ភាគីដែលបានស្នើសុំប្រសិនបើមិនមានសក្ខីកម្មរបស់សាក្សីរូបនោះទេ និង(៣) សិទ្ធិរបស់ជនជាប់ចោទមិនត្រូវបានប៉ះពាល់ ក្នុងការតទល់ជាមួយនឹងសាក្សីរូបនោះ[10]។ ទោះយ៉ាងណាក៏ដោយ សំណើមិន

[9] **E236/1/1/2** សំណើ, កំណត់សម្គាល់លេខ៤*ខាងដើម* ត្រង់កថាខណ្ឌ១០។

[10] *រដ្ឋអាជ្ញា ទល់នឹង Jovica Stanišić*, សំណុំរឿងលេខ: IT-03-69-T, សេចក្តីសម្រេចលើញត្តិរបស់សហព្រះរាជអាជ្ញាស្នើសុំស្តាប់សវនាការសាក្សីតាមការប្រព័ន្ធសោតទស្សន៍ (អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY), ២៤ កុម្ភៈ ២០១០ ត្រង់កថាខណ្ឌ៨ (លើកយោង

បានពិចារណាថា ក្រៅពីលក្ខខណ្ឌវិនិច្ឆ័យទាំងនេះ និងកត្តាពាក់ព័ន្ធផ្សេងៗទៀត នៅក្នុងករណីជាក់លាក់ណាមួយ ការសម្រេចជាចុងក្រោយរបស់អង្គជំនុំជម្រះ គឺតើសក្ខីកម្មធ្វើតាមប្រព័ន្ធសោតទស្សន៍ស្ថិតក្នុងផលប្រយោជន៍នៃយុត្តិធម៌ដែរ ឬអត់[11]។

៩- សហព្រះរាជអាជ្ញាយល់ស្របជាមួយមេធាវីការពារក្ដីថា ករណីយុត្តិសាស្ត្ររបស់តុលាការពិសេសនេះ គឺពាក់ព័ន្ធនឹងការបកស្រាយត្រឹមត្រូវនៃវិធាន២៦ និងថាភាគីដើមបណ្ដឹងរដ្ឋប្បវេណីស្ថិតក្នុងកាលៈទេសៈស្រដៀងគ្នានឹងអ្នកជំនាញ និងសាក្សីធម្មតាដែរទាក់ទិននឹងចំណុចនេះ[12]។ សហព្រះរាជអាជ្ញាសន្និដ្ឋានបន្ថែមថា ការខ្លឹមសារត្រឹមត្រូវនៃវិធាន២៦ - ក្នុងស្មារតីនៃគោលការណ៍ជាមូលដ្ឋាននៃការការពារផលប្រយោជន៍របស់ភាគី និងជនរងគ្រោះ[13] ដោយរក្សាបាន "តុល្យភាពរវាងសិទ្ធិរបស់គូភាគី"[14] និងការគោរពសិទ្ធិរបស់ជនរងគ្រោះនូវគ្រប់កិច្ចដំណើរការនីតិវិធី[15]-ការធានាចំពោះកត្តា "ផលប្រយោជន៍នៃយុត្តិធម៌" ដូចបានពិចារណានៅក្នុងយុត្តិសាស្ត្រ ស្ដីពីការផ្ដល់សក្ខីកម្មរបស់តុលាការ ICTY តាមរយៈប្រព័ន្ធសោតទស្សន៍។

១០- ក៏ប៉ុន្តែ ការអះអាងរបស់មេធាវីការពារក្ដី ទាក់ទិននឹងផលប៉ះពាល់នៃការផ្ដល់សក្ខីកម្ម តាមរយៈប្រព័ន្ធសោតទស្សន៍ចំពោះសិទ្ធិក្នុងការតទល់នឹងសាក្សី[16] គឺជាការមិនត្រឹមត្រូវឡើយនៅក្នុងច្បាប់។ ករណីយុត្តិសាស្ត្ររបស់តុលាការ ICTY នៅលើលក្ខណៈវិនិច្ឆ័យទី៣ ពាក់ព័ន្ធនឹងសិទ្ធិក្នុងការតទល់ជាមួយនឹងសាក្សី នៅតែស្របគ្នា (ទោះបីជាមានការអភិវឌ្ឍន៍ខាងផ្នែកបច្ចេកវិទ្យាគួរឲ្យកត់សម្គាល់យ៉ាងណាក្ដី) ចាប់តាំងពីទសវត្សរ៍១៩៩៧ ដល់២០០៦។ ក្នុងដំណាក់កាលដំបូងនៃរឿងក្ដី *Delalić និងគូកន,* អង្គជំនុំជម្រះសាលាដំបូងបានកំណត់យ៉ាងដូច្នេះថា៖

---

*រដ្ឋអាជ្ញា ទល់នឹង Gotovina នឹងគូកន,* សំណុំរឿងលេខ: IT-06-90-T, សម្អាងហេតុសម្រាប់សេចក្ដីសម្រេចក្នុងការអនុញ្ញាតតាមសំណើរបស់ការិយាល័យរដ្ឋអាជ្ញាដើម្បីសួរសាក្សីរបស់ភាគីបដិបក្ខបួនរូបដែលបានស្នើឡើង តាមវិធាន៩២*ស្ទួន* និងសម្អាងហេតុសម្រេចសេចក្ដីសម្រេចស្ដាប់ភ័ស្តុតាងសាក្សីទាំងនោះតាមប្រព័ន្ធសោតទស្សន៍ (អង្គជំនុំជម្រះសាលាដំបូង I នៃតុលាការ ICTY I), ៣ វិច្ឆិកា ២០០៩ ត្រង់កថាខណ្ឌ៧)។

[11] *ក្នុងឯកសារដដែលដូចខាងលើ*។

[12] **E236/1/1/2** សំណើ, កំណត់សម្គាល់លេខ៤*ខាងដើម* ត្រង់កថាខណ្ឌ១០។

[13] វិធាន២១(១) នៃវិធានផ្ទៃក្នុង។

[14] វិធាន២១(១)(ក) នៃវិធានផ្ទៃក្នុង។

[15] វិធាន២១(១)(គ) នៃវិធានផ្ទៃក្នុង។

[16] **E236/1/1/2** សំណើ, កំណត់សម្គាល់លេខ៤*ខាងដើម* ត្រង់កថាខណ្ឌ១០, ១៤-១៨។

*ការភ្ជាប់ប្រព័ន្ធសោតទស្សន៍ តាមពិត គឺគ្រាន់តែការពង្រីកមួយរបស់អង្គជំនុំជម្រះសាលាដំបូងឱ្យបានទៅដល់ទីកន្លែងរបស់សាក្សី។ ហេតុដូច្នេះ ជនជាប់ចោទក៏មិនត្រូវបានបដិសេធសិទ្ធិក្នុងការតទល់ជាមួយសាក្សី និងក៏មិនបានបាត់បង់ដោយពិតប្រាកដ ដោយសារអវត្តមានបុគ្គលផ្ទាល់ខ្លួននៃសាក្សីរូបនោះដែរ។ អាស្រ័យហេតុនេះគេមិនអាចលើកយកយុត្តិកម្មណាមួយមកនិយាយថា សក្ខីកម្មដែលផ្តល់តាមរយៈប្រព័ន្ធសោតទស្សន៍គឺជារំលោភសិទ្ធិរបស់ជនជាប់ចោទ ក្នុងការតទល់ជាមួយសាក្សីនោះឡើយ។ មាត្រា២១(៤)(ង) [នៃច្បាប់លក្ខន្តិកៈរបស់ ICTY][17] គឺគ្មានការរំលោភឡើយ[18]។*

១១- នៅក្នុងសេចក្តីសម្រេចនៃរឿងក្តី *Delalić* ក៏បានយកតាមការសម្រេចពីមុនក្នុងរឿងក្តី *Tadić* ដែរដែលថាតម្លៃភ័ស្តុតាងនៃសក្ខីកម្មដែលបានផ្តល់តាមរយៈប្រព័ន្ធសោតទស្សន៍ មិនមានទម្ងន់ដូចគ្នានឹងសក្ខីកម្មដែលបានផ្តល់នៅក្នុងសាលសវនាការ[19] ប៉ុន្តែដោយមានការប្រយ័ត្ន ការរក្សាបាននូវទម្ងន់ដូច្នេះគឺជា "បញ្ហានៃការវាយតម្លៃរបស់អង្គជំនុំជម្រះ នៅពេលវាយតម្លៃភ័ស្តុតាងជារួម ដើម្បីកំណត់ថាតើសាក្សីម្នាក់ៗគួរឱ្យជឿជាក់បានកម្រិតណា"[20]។ ប៉ុន្តែ ទាក់ទិននឹងចំណុចនេះ យុត្តិសាស្ត្ររបស់ ICTY បានវិវឌ្ឍន៍យ៉ាងច្រើនមកដល់ឆ្នាំ២០០៦។ ជាឧទាហរណ៍ ក្នុងរឿងក្តី *Milutinović* អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសង្ខេបពីស្ថានភាពនៃច្បាប់ជាធរមាន ដូចខាងក្រោមនេះ ៖

*យុត្តិសាស្ត្ររបស់តុលាការនេះ គាំទ្រចំពោះអំណះអំណាងថា សក្ខីកម្មរបស់សាក្សីធ្វើតាមរយៈប្រព័ន្ធសោតទស្សន៍គួរតែទទួលបានទម្ងន់ភស្តុតាងដូចគ្នានឹងសក្ខីកម្មដែលបានផ្តល់ក្នុងសាល*

[17] ច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, U.N. Doc S/RES/827 (២៥ ឧសភា ១៩៩៣), មាត្រា២១(៤)(ង): "ជនជាប់ចោទត្រូវមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមាដូចខាងក្រោម និងប្រកបដោយគុណភាពពេញលេញ: [...] ដើម្បីដេញដោល ឬ បានដេញដោលសាក្សីប្រឆាំងនឹងខ្លួន និងដើម្បីទទួលបានការបង្ហាញខ្លួនរបស់សាក្សី និងការសួរដេញដោលសាក្សីតាមនាមខ្លួនគាត់ ក្រោមលក្ខខណ្ឌដូចគ្នានឹងសាក្សីដែលប្រឆាំងរូបគាត់ដែរ"។

[18] *រដ្ឋអាជ្ញា ទល់នឹង Zejnil Delalić និងគូកន (ឥឡូវហៅថា Mucić នឹងគូកន.,)*, សំណុំរឿងលេខ: IT-96-21, សេចក្តីសម្រេចលើញត្តិស្នើសុំឱ្យអនុញ្ញាតសាក្សី K,L, និង M ផ្តល់សាក្សីកម្មរបស់ពួកគេតាមមធ្យោបាយប្រព័ន្ធសោតទស្សន៍ (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ២៨ ឧសភា ១៩៩៧ ត្រង់កថាខណ្ឌ១៥។

[19] *រដ្ឋអាជ្ញា ទល់នឹង Dusko Tadić*, សំណុំរឿងលេខ: IT-94-1-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ស្នើឱ្យកោះហៅនិងការពារសាក្សីរបស់មេធាវីការពារក្តី, និងស្តីពីការផ្តល់ភ័ស្តុតាងតាមរយៈប្រព័ន្ធសោតទស្សន៍, ២៥ មិថុនា ១៩៩៦ ត្រង់កថាខណ្ឌ២១។

[20] *Delalić នឹងគូកន.*, សេចក្តីសម្រេចលើ VCL របស់អង្គសវនាការនៃតុលាការ ICTY, កំណត់សម្គាល់លេខ២៥*ខាងដើម* ត្រង់កថាខណ្ឌ១៨។

*<u>សវនាការ</u> និងថាដូច្នេះវិធានការបែបនេះ <u>មិនរំលោភសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការសួរសាក្សីរបស់ភាគីបដិបក្ខ និងការសួរតទល់ជាមួយសាក្សីដោយផ្ទាល់ឡើយ</u>*[21] ។

១២- ដោយឈរលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា គ្មានមូលដ្ឋានផ្លូវច្បាប់សម្រាប់ឲ្យមេធាវីការពារក្តីធ្វើអំណះអំណាងថា "ការអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 ផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់លោក អៀង សារី ក្នុងការតទល់ដោយផ្ទាល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ" ឡើយ។ យោងតាមច្បាប់ជាធរមាន និងដែលផ្ទុយទៅនឹងទម្លាប់នៃការអនុវត្តនៅសហរដ្ឋអាមេរិក និងយុត្តាធិការដែនដីរបស់ប្រទេសនេះ ការតទល់តាមរយៈប្រព័ន្ធសោតទស្សន៍ គឺយោងទៅតាមរបៀបដែលអង្គជំនុំជម្រះតែងបង្គាប់ឲ្យធ្វើ គឺមានន័យដូចគ្នានឹងការតទល់ជាមួយបុគ្គលដោយផ្ទាល់ដែរ។

១៣- ក្នុងខណៈដែលចរិតលក្ខណៈនៃ "ការលើកលែង" ចំពោះសក្ខីកម្មធ្វើតាមរយៈប្រព័ន្ធសោតទស្សន៍ ត្រូវបានលើកយោងនៅក្នុងសេចក្តីសម្រេចពីមុនមួយរបស់អង្គជំនុំជម្រះ[22] មេធាវីការពារក្តីទំនងជាឲ្យយោបល់ថា ពាក្យថា "នៅពេលណាដែលអាចធ្វើទៅបាន" ដែលមានចែងនៅក្នុងវិធាន២៦ ដាក់កម្រិតលក្ខខណ្ឌតឹងរ៉ឹងដោយពុំត្រឹមត្រូវនៃការរៀបចំភ័ស្តុតាងវេជ្ជសាស្ត្រសត្យានុម័ត ដើម្បីបំពេញចិត្តមេធាវីការពារក្តី ក្នុងនាមជាអ្នកត្រួតពិនិត្យដែលបានតែងតាំងដោយខ្លួនឯង លើភាពត្រឹមត្រូវរបស់អង្គជំនុំជម្រះ[23]។ ចរិតលក្ខណៈពិសេសនៃភ័ស្តុតាងតាមរយៈប្រព័ន្ធសោតទស្សន៍ មិនបានយកមកធ្វើជាយុត្តិកម្មដោយឈរលើមូលដ្ឋានថា នឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទដោយរបៀបណាមួយ និងថាបើដូច្នេះគួរត្រូវបានប្រើតែបន្តិចបន្តួច។ ផ្ទុយទៅវិញ ការណ៍នេះធ្វើដូចជារបាំងការពារមួយ

[21] *រដ្ឋអាជ្ញា ទល់នឹង Milan Milutinović និងគូកន.*, សំណុំរឿងលេខ: IT-05-87-T, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញាស្នើសុំវិធានការការពារ និងស្តាប់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍, ១៥ សីហា ២០០៦ ត្រង់កថាខណ្ឌ៣។

[22] **E166/1/4** "សក្ខីកម្មដែលបានស្នើឡើងរបស់ Benedict Kiernan នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ១៣ មិថុនា ២០១២ ត្រង់ទំព័រ១។

[23] **E236/1/1/2** សំណើ, កំណត់សម្គាល់លេខ៤*ខាងដើម* ត្រង់កថាខណ្ឌ១៧ ("គ្រាន់តែ អង្គជំនុំជម្រះសាលាដំបូងមិនបានបង្ហាញថាមានកាលៈទេសៈពិសេសដើម្បីគាំទ្រចំពោះសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 ដើម្បីផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍)។

"ដើម្បីប្រឆាំងនឹងការរំលោភបំពាននៃការទទួលបានអត្ថប្រយោជន៍"[24] ស្របទៅនឹងកង្វល់ចំពោះ "ការបង្ហាញឲ្យឃើញជាក់ស្តែង"[25] នៃកិច្ចដំណើរការនីតិវិធីខឡារិក។

១៤- ដោយយោងលើសារៈសំខាន់នៃភាពជាប់ពាក់ព័ន្ធក្នុងការផ្តល់សក្ខីកម្មរបស់សាក្សីថា ជាកត្តាមួយជាប់ទាក់ទងទៅការវាយតម្លៃអំពីផលប្រយោជន៍នៃយុត្តិធម៌ មេធាវីការពារក្តីបានស្នើឡើងថាអង្គជំនុំជម្រះរកមិនឃើញអំពីសារៈសំខាន់នៃការផ្តល់សក្ខីកម្មរបស់សាក្សីដែលបានរំពឹងទុកនោះឡើយ"[26]។ ក្នុងខណៈដែលមិនមានការរកឃើញបែបនេះ នៅក្នុងអត្ថបទនៃសេចក្តីសម្រេចរបស់ខ្លួននោះ កំណត់ហេតុនៃដំណើរការនីតិវិធីបង្ហាញឲ្យឃើញច្បាស់ថា អង្គជំនុំជម្រះបានចាត់ទុកថា ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 គឺជាបុគ្គលមួយរូប "ដែលជាប់ទាក់ទងខ្លាំងជាងគេបំផុត" ទៅនឹងវគ្គនៃសវនាការបច្ចុប្បន្ននេះ[27]។ មេធាវីការពារក្តីក៏បានប្រកាន់យកជំហរដដែលថា "សក្ខីកម្មរបស់សាក្សី TCCP-1 មិនមានសារៈសំខាន់ជួយដល់សហព្រះរាជអាជ្ញា ក្នុងការបង្ហាញនូវបន្ទុកភ័ស្តុតាងរបស់ខ្លួនឡើយ ឬមិនអាចជួយដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការរកឲ្យឃើញនូវការពិត នៅក្នុងសំណុំរឿងលេខ ០០២/០១"[28] ខណៈដែលក្នុងពេលបច្ចុប្បន្ននេះមានការអះអាងថាដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 ទំនងជាដាក់បន្ទុកលើជនជាប់ចោទ អៀង សារី[29]។

១៥- ការអង្កេតបឋមមួយរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ស្តីពីការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ត្រូវបានផ្តល់ជូននៅក្នុង**ឧបសម្ព័ន្ធទី១**។ តារាងវិភាគនេះបង្ហាញថា មានសេចក្តីសម្រេចចំនួន៣១ ត្រូវបានអង្កេតរួច (ដែលក្នុងនោះរួមមានសំណើរបស់អយ្យការចំនួន២៣ និងសំណើរបស់មេធាវីការពារក្តីចំនួន៨) អង្គជំនុំជម្រះដែលពាក់ព័ន្ធ បានអនុញ្ញាតឲ្យប្រើប្រព័ន្ធសោតទស្សន៍ (សម្រាប់សាក្សីមួយចំនួន ឬទាំងអស់ដែលបានស្នើសុំ)នៅក្នុងករណីចំនួន៣០ និងបដិសេធលើសំណើមួយតែប៉ុណ្ណោះ។ សេចក្តីសម្រេចមួយចំនួនទាក់ទងនឹងពាក្យសុំ ដើម្បីផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធ

---

[24] *Delalić នឹងគូកន.*, សេចក្តីសម្រេចរបស់សវនាការនៃតុលាការ ICTY ស្តីពី VCL, កំណត់សម្គាល់២៥*ខាងដើម* ត្រង់កថាខណ្ឌ១៧។

[25] សូមអាន ក្រសួងយុត្តិធម៌ (ប្រទេសនូវ៉ែលហ្សេឡង់), "ការតភ្ជាប់បណ្តាញសោតទស្សន៍ នៅក្នុងកិច្ចដំណើរការនីតិវិធីAudio Links and Audio Visual Links in Proceedings" ឯកសារសម្រាប់ពិភាក្សា CLW-38-17,ចុះថ្ងៃទី២៨ វិច្ឆិកា ២០០៨ត្រង់កថាខណ្ឌទី៨៧។

[26] ឯកសារលេខ **E236/1/1/2** សំណើ, កំណត់សំគាល់*លេខ២៤ ខាងដើម* ត្រង់កថាខណ្ឌទី១៣។

[27] ឯកសារលេខ **E236/1** អនុស្សរណៈ, កំណត់សំគាល់*លេខ១ ខាងដើម* ត្រង់កថាខណ្ឌទី១។

[28] ឯកសារលេខ **E236/1/1/2** សំណើ, កំណត់សំគាល់*លេខ២៤ ខាងដើម* ត្រង់កថាខណ្ឌទី១៣។

[29] ដូចគ្នានឹងខាងលើ ត្រង់កថាខណ្ឌទី១៥ ។

សោតទស្សន៍ដោយសារហេតុផលមានជម្ងឺ និងមានទុក្ខកង្វល់ខាងផ្លូវអារម្មណ៍[30]។ ទាំងអស់នេះត្រូវបានពិនិត្យពិចារណាដូចមានខាងក្រោមនេះ៖

## III. យុត្តិសាស្ត្ររបស់តុលាការ ICTY ព្រមទទួលយកការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នៅក្នុងករណីស្តីពីបញ្ហាជម្ងឺដែលមាន ឬមិនមានលិខិតបញ្ជាក់របស់ពេទ្យ

១៦- យុត្តិសាស្ត្ររបស់តុលាការ ICTY ដែលត្រូវបានអង្កេតមើល នៅក្នុង**ឧបសម្ព័ន្ធទី I** បង្ហាញឱ្យឃើញថា ស្ថានភាពមានជម្ងឺ ឬមានទុក្ខកង្វល់ខាងផ្លូវអារម្មណ៍របស់សាក្សីដែលជាជនរងគ្រោះម្នាក់ គឺជាកត្តាដែលមានការជាប់ទាក់ទងសម្រាប់ប្រើប្រាស់ក្នុងការវាយតម្លៃអំពីផលប្រយោជន៍នៃយុត្តិធម៌ ក្នុងការអនុញ្ញាតឱ្យផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍។ គឺមិនសម្អាងតែលើកត្តាមានជម្ងឺ សម្រាប់ជាមូលហេតុផ្ទាល់នៃក្តីកង្វល់របស់អង្គជំនុំជម្រះ ដោយមិនគិតពីបញ្ហាមិនមានលទ្ធភាពទៅ ឬមិនមានឆន្ទៈទៅរបស់សាក្សីក្នុងការធ្វើដំណើរទៅផ្តល់សក្ខីកម្មដោយផ្ទាល់ ដែលអាចជាមូលហេតុបណ្តាលមកពីមានជម្ងឺ មានកង្វល់ផ្នែកអារម្មណ៍ ឬមានការព្រួយបារម្ភចំពោះបញ្ហាផ្ទាល់ខ្លួនផ្សេងទៀត បញ្ហាគ្រួសារ ឬបញ្ហាសន្តិសុខ។ បញ្ហាទាំងអស់ខាងលើនេះ អាចត្រូវបានបញ្ជាក់ជូនដោយលិខិតបញ្ជាក់របស់គ្រូពេទ្យ របាយការណ៍របស់អង្គភាពគាំពារសាក្សីដែលមានវិជ្ជាជីវៈ ឬសូម្បីតែសេចក្តីប្រកាសផ្ទាល់ខ្លួនរបស់សាក្សីជាដើម។

១៧- នៅក្នុងកណីរឿងក្តីរបស់ *Stanisić* រដ្ឋអាជ្ញាបានដាក់សំណើមួយសុំឱ្យសាក្សីបីនាក់មកផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ដោយសារសាក្សីមិនមានលទ្ធភាពធ្វើដំណើរទៅកាន់ទីតាំងតុលាការបានដោយសារមូលហេតុគាត់មានវ័យចំណាស់ មានជម្ងឺ ឬមានមូលហេតុសមស្របក្នុងការមិនចង់ធ្វើដំណើរ។ រដ្ឋអាជ្ញាបានពោលអះអាងថា សាក្សីមួយរូបមិនអាចមានលទ្ធភាពធ្វើដំណើរបានដោយសារមានសម្ពាធឈាមខ្ពស់ និងភ័យខ្លាចមិនហ៊ានជិះយន្តហោះដែលអាចធ្វើឱ្យសម្ពាធឈាមខ្ពស់មានសភាពកាន់តែធ្ងន់ឡើងថែមទៀត។ សាក្សីទីពីរមានស្ថានភាពបេះដូងមិនសូវស្រួល ហើយព្រមទាំងស្ថិតនៅក្នុង "ស្ថានភាពផ្លូវអារម្មណ៍ដែលកំពុងតែប្រឈមមុខយ៉ាងខ្លាំង"ផងដែរ ដោយសារតែបាត់បង់ដៃគូ

[30] សូមអាន ករណីរឿងក្តីរបស់ *Stanišić* , សេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ស្តីពី VCL, កំណត់សំគាល់លេខ១៧ *ពីខាងដើម* ។ ករណីរឿងក្តីរបស់ *Delalić និងគូរកន,* សេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ស្តីពី VCL, កំណត់សំគាល់លេខ២៥ *ពីខាងដើម*។

របស់សាក្សីនោះ។ សាក្សីទីបីដែលមិនអាចធ្វើដំណើរបាន ព្រោះដោយសារតែអាយុច្រើនពេក និងរាងកាយមិនមួនក៏ដូចជាស្ថានភាពបាត់បង់ដៃគូរបស់សាក្សីដែរ[31]។ សម្រាប់ពាក្យសុំនីមួយៗខាងអយ្យការបានផ្តល់ជូននូវឯកសារពេទ្យមួយចំនួនដែលគាំទ្រចំពោះសារណាដែលថាសាក្សីមិនមានលទ្ធភាពទៅ ឬមានមូលហេតុសមស្របក្នុងការមិនចង់ធ្វើដំណើរទៅកាន់ទីក្រុងឡាអេ[32]។

១៨- តុលាការបានវាយតម្លៃលើឯកសារភ័ស្តុតាងសម្រាប់ពាក្យសុំនីមួយៗ[33]។ សម្រាប់ពាក្យសុំទីមួយ តុលាការបានរកឃើញថា របាយការណ៍មួយរបស់វេជ្ជបណ្ឌិតក៏ដូចជាព័ត៌មានផ្សេងៗទៀតអំពីកាលៈទេសៈផ្ទាល់ខ្លួនរបស់សាក្សីដែលអាចគាំទ្រដល់ពាក្យសុំ។ នៅក្នុងពាក្យសុំទីពីរ អង្គជំនុំជម្រះបានកត់សម្គាល់ចំពោះលិខិតដែលហួសកាលបរិច្ឆេទមួយស្តីពីស្ថានភាពសុខភាពរបស់សាក្សីដែលមិនត្រឹមត្រូវសម្រាប់ប្រើនៅក្នុងពាក្យសុំ ប៉ុន្តែបានរកឃើញកាលៈទេសៈផ្ទាល់ខ្លួន និងវ័យចាស់ជរារបស់សាក្សីដែលបានគាំទ្រដល់ពាក្យសុំ[34]។ ចំពោះសាក្សីទីបី ជាថ្មីម្តងទៀត តុលាការបានកត់សម្គាល់ឃើញថាភ័ស្តុតាងដែលពេទ្យបានផ្តល់ឲ្យគឺហួសកាលបរិច្ឆេទ មិនអាចធ្វើជាភ័ស្តុតាងគាំទ្រអំពីការអះអាងរបស់ពេទ្យបានឡើយ ប៉ុន្តែនៅតែរកឃើញជាដដែលថា មិនមាន "មូលហេតុក្នុងការបង្ហាញនូវមន្ទិលសង្ស័យចំពោះការព្រួយបារម្ភដែលបានលើកឡើងដោយសាក្សីទៅកាន់ខាងអយ្យការនោះឡើយ" ហើយបានអនុញ្ញាតចំពោះពាក្យសុំ[35]។

១៩- នៅក្នុងករណីរឿងក្តីរបស់ *Mucić និងគូរកន* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានរកឃើញថា ផ្អែកលើភ័ស្តុតាងរបស់ពេទ្យដែលត្រូវបានផ្តល់ជូនដោយអយ្យការថា មានសាក្សីចំនួនពីរនាក់មិនមានលទ្ធភាពធ្វើដំណើរទៅកាន់ទីក្រុងឡាអេបានទេ ដោយសារស្ថានភាពសុខភាពដែលមាន "សភាពធ្ងន់ធ្ងរ និងមិនអាចធូរស្រាលបានទេ សូម្បីតែបានព្យាបាលមួយរយៈពេលមកហើយនោះក្តី"[36]។ ទោះបីជាក្រុមមេធាវីការពារក្តីបានជំទាស់ថា ភ័ស្តុតាងដែលពេទ្យបានផ្តល់ជូននោះ មាន

---

[31]ករណីរឿងក្តីរបស់ *Stanišić* , សេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ស្តីពី VCL, កំណត់សំគាល់លេខ១៧ *ពីខាងដើម* ត្រង់កថាខណ្ឌទី៤។

[32] *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌទី១២-១៤។

[33] *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌទី១២។

[34] *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌទី១៣។

[35] *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌទី១៤។

[36] ករណីរឿងក្តីរបស់ *Delalić និងគូរកន,* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY លើ VCL, កំណត់សំគាល់ទី២៥ ពីខាងដើម ត្រង់កថាខណ្ឌទី២។

លក្ខណៈមិនគ្រប់គ្រាន់ក៏ដោយ ក៏អង្គជំនុំជម្រះ "ទទួលថាឯកសារដែលដាក់ជូនដោយអយ្យការស្តីពីស្ថានភាពសុខភាពដែលបានចោទប្រកាន់ គឺគ្រប់គ្រាន់ហើយ" ដោយបញ្ជាក់ថាមិនអាចធ្វើដំណើរទៅកាន់ទីក្រុងឡាអេបានទេ[37]។

២០- នៅក្នុងករណីរឿងក្តីរបស់ *Gotovina និងគូរកន* ដំបូងឡើយ អង្គជំនុំជម្រះបានរកឃើញថា នៅក្នុងរបាយការណ៍របស់ពេទ្យ មិនបានបញ្ជាក់អំពីលក្ខខណ្ឌណាមួយបានច្បាស់លាស់ គ្រប់គ្រាន់ដើម្បីធ្វើយុត្តិកម្មអំពីការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍មួយជំនួសឱ្យការផ្តល់សក្ខីកម្ម នៅក្នុងតុលាការនោះទេ[38]។ ភ្លាមៗបន្ទាប់ពីអយ្យការបានធ្វើញត្តិមួយសាជាថ្មីម្តងទៀត ព្រមជាមួយនឹងរបាយការណ៍បច្ចុប្បន្នភាពរបស់ពេទ្យលើកទីពីរនិយាយថា សាក្សីត្រូវបានធ្វើរោគវិនិច្ឆ័យដោយមានលក្ខខណ្ឌតម្រូវឱ្យធ្វើការវះកាត់ជាបន្ទាន់។ ដោយបានពិចារណាទៅលើព័ត៌មាននេះ អង្គជំនុំជម្រះបានអនុញ្ញាតលើសំណើឱ្យសាក្សីផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍[39]។

២១- ជាសរុបមក តាមការពិនិត្យមើលបឋមអំពីយុត្តិសាស្ត្រដែលមាននៅក្នុង**ឧបសម្ព័ន្ធទី I** មានទំនោរទៅគាំទ្រចំពោះសំណើដែលសុំឱ្យមានលិខិតបញ្ជាក់របស់ពេទ្យជាង ក៏ប៉ុន្តែមិនកំណត់ទេ នៅក្នុងករណីដែលអនុញ្ញាតឱ្យធ្វើសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ដោយសារតែមានជម្ងឺនោះទេ។ តែផ្ទុយទៅវិញ គឺជាបច្ច័យនៃបញ្ហាខាងសុខភាពដែលប៉ះពាល់លើលទ្ធភាព និងឆន្ទៈរបស់សាក្សីក្នុងការធ្វើដំណើរទៅកាន់ទីតាំងតុលាការនោះដែលជាកត្តាចម្បងមួយ ក្នុងការអនុញ្ញាតឱ្យផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍។ ថ្វីត្បិតតែយ៉ាងនេះក្តី ក៏សហព្រះរាជអាជ្ញាសូមលើកអនុសាសន៍ថាភ័ស្តុតាងរបស់ពេទ្យគួរតែត្រូវបានប្រើប្រាស់ជាមធ្យោបាយមួយសម្រាប់លើកកម្ពស់តម្លាភាពនៅក្នុងកិច្ចដំណើរការនីតិវិធី។

---

[37] *ដូចគ្នានឹងខាងលើកន្លែងដែល* ត្រង់កថាខណ្ឌទី២០។

[38] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Ante Gotovina និងគូកន*, សំណុំរឿងលេខ IT-06-90-T, មូលហេតុដែលនាំឱ្យធ្វើសេចក្តីសម្រេចលើញត្តិដែលធ្វើសាឡើងវិញរបស់អយ្យការដែលសុំឱ្យបង្ហាញភ័ស្តុតាងរបស់សាក្សីលេខ៨២ តាមរយៈប្រព័ន្ធសោតទស្សន៍ ពីទីក្រុង Zagreb និងមូលហេតុដែលនាំឱ្យធ្វើសេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីរបស់ Markax ដើម្បីឱ្យធ្វើការសួរដេញដោលសាក្សីរបស់ភាគីបដិបក្ខ នៅក្នុងទីក្រុង Zagreb (អង្គជំនុំជម្រះសាលាដំបូងទី I របស់តុលាការ ICTY), ចុះថ្ងៃទី២៦ កុម្ភៈ ២០០៩, ត្រង់កថាខណ្ឌទី៣។

[39] *ដូចគ្នានឹងខាងលើកន្លែងដដែល* . ត្រង់កថាខណ្ឌទី២១។

## III. ដំណោះស្រាយដែលបានស្នើសុំ

២២- អាស្រ័យដោយមូលហេតុដូចបានជម្រាបជូនខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើដោយគោរព ដល់អង្គជំនុំជម្រះមេត្តា៖

ក) **បដិសេធចោល**សំណើនេះទាំងស្រុង និង

ខ) ដំណើរការក្នុងការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 តាមរយៈប្រព័ន្ធសោតទស្សន៍ទៅតាមកាលបរិច្ឆេទដែលបានគ្រោងទុក៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |